ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

-សំណុំរឿងរដ្ឋប្បវេណី លេខ ៤០១
ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨
-សាលក្រម លេខ ១៧ "យ"
ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃព្រហស្បតិ៍ ៩រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ និងប្រកាសសាលក្រម ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ នៅសាលជំនុំជម្រះនៃ សាលាដំបូង ខេត្តសៀមរាប លើសំណុំរឿងរដ្ឋប្បវេណី លេខ៖ ៤០១ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ ដោយមានសមាសភាពដូចតទៅ៖

## ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ចៅក្រមសាលាដំបូង ខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តសៀមរាប

-ដើមចោទឈ្មោះ [redacted] សំណាង ភេទប្រុស កើតនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៨៣ ជនជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

-ចុងចម្លើយឈ្មោះ [redacted] ស្រីប៉ិច ភេទស្រី កើតនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៨៧ ជនជាតិខ្មែរ អាសយដ្ឋាន [redacted]។

## អង្គហេតុ និងចំណុចវិវាទ

I-ការទាមទាររបស់ដើមចោទ៖

ដើមចោទបានប្តឹងសុំទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោម:

១.សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីប៉ិច ចាប់ពីពេលនេះតទៅ។

២.ឲ្យចុងចម្លើយមានសិទ្ធិអំណាចមេបាលើកូនស្រីម្នាក់ឈ្មោះ [redacted] ដានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥។

៣.ទ្រព្យសម្បត្តិរួមមាន៖ ដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នងសង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣



Scanned with CamScanner

១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប លក់ដើម្បីសងបំណុលធនាគារ លុយដែលនៅសល់ចែងជាពីរចំណែកស្មើគ្នា។

**៤**.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

II-ការទាមទាររបស់ចុងចម្លើយៈ

ចុងចម្លើយបានប្តឹងសុំទាមទារឲ្យតុលាការចេញសាលក្រមដូចខាងក្រោមៈ

**១**.បែងចែកបំណុលរួមដូចខាងក្រោមៈ

-បំណុលជំពាក់ធនាគារ អេស៊ីលីដា នៅសល់ ចំនួន ៧៧.០០០ (ប្រាំពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក។

-បំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាយនែន នៅសល់ ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក។

-បំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ នៅសល់ ចំនួន ១.២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក។

-បំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហពាណិជ្ជ នៅសល់ ចំនួន ៦.៥០០ (ប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក។

**២**.ឲ្យដើមចោទបង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន ចំនួន ៤៥០ (បួនរយហាសិប) ដុល្លារអាមេរិក។

III-ការពន្យល់ត្រួសៗអំពីរឿងក្តីៈ

ដើមចោទឈ្មោះ [redacted] **សំណាង** ភេទប្រុស និងចុងចម្លើយឈ្មោះ [redacted] ស្រីប៊ុច ភេទស្រី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ដូចក្នុងបញ្ជាក់ក្នុងសំបុត្រអាពាហ៍ពិពាហ៍ លេខ ១៥៨ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់សំបួរ។ ក្នុងចំណងអាពាហ៍ពិពាហ៍ដើមចោទ និងចុងចម្លើយ មានកូនចំនួនមួយនាក់ គឺឈ្មោះ [redacted] ដានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ និងដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ជាទ្រព្យសម្បត្តិរួម ប៉ុន្តែមានបំណុលរួមគ្នាមួយចំនួនទៀត។ ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ដើមចោទបានសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះ ហើយចុងចម្លើយក៏បាន



Scanned with CamScanner

យល់ព្រម ដោយដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នាអំពីអ្នកមានសិទ្ធិអំណាចមេបាលើកូន ទ្រព្យសម្បត្តិរួម ប៉ុន្តែមានចំណុចវិវាទត្រង់បំណុលរួម។

IV.សេចក្តីថ្លែងការណ៍របស់គូភាគី

ឈ្មោះ [redacted] ស្រីប៉ិច ជាចុងចម្លើយបានថ្លែងការណ៍ថា ខ្លួននៅតែសុំលែងលះ សុំសិទ្ធិចិញ្ចឹមកូន ចំពោះទ្រព្យរួម មានដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប យល់ព្រមលក់ ដើម្បីសងបំណុលធនាគារ ហើយលុយនៅសល់បែងចែងជាពីរចំណែកស្មើគ្នា ដូចការព្រមព្រៀង ក្នុងនីតិវិធីត្រៀមលើកមុនដែរ ហើយដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី នោះមានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦។ ចំពោះបំណុលរួមខ្លួន ទាមទារដូចក្នុងបណ្តឹងតប ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ របស់ខ្លួនដដែល គឺមានបំណុលជំពាក់ធនាគារ អេស៊ីលីដា នៅសល់ ចំនួន ៧៧.០០០ (ប្រាំពីរម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក, បំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វាយនែននៅសល់ ចំនួន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារអាមេរិក, បំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ នៅសល់ ចំនួន ១.២០០ (មួយពាន់ពីររយ) ដុល្លារអាមេរិក និងបំណុលជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សហពាណិជ្ជ នៅសល់ ចំនួន ៦.៥០០ (ប្រាំមួយពាន់ប្រាំរយ) ដុល្លារអាមេរិក ស្នើសុំតុលាការបែងចែកសងទៅម្ចាស់បំណុលជាពីរចំណែកស្មើគ្នា។ អាហារកាតព្វកិច្ចយល់ព្រមឲ្យឈ្មោះ សែន សំណាង បង់តាមលទ្ធភាពដដែល។

ឈ្មោះ [redacted] បូរី ជាសាក្សីបានធ្វើសេចក្តីថ្លែងការណ៍ថា អ្នកដែលជួយខ្ចីលុយឲ្យឈ្មោះ [redacted] ស្រីប៉ិច និងឈ្មោះ [redacted] សំណាង គឺឈ្មោះ [redacted] រ៉ាឌី , ឈ្មោះ [redacted] សាវណា និងឈ្មោះ [redacted] បញ្ញា ដោយសារឈ្មោះ [redacted] ស្រីប៉ិច និងឈ្មោះ [redacted] សំណាង ជាប់បំណុលច្រើនពេក ធនាគារ គេលែងឲ្យខ្ចី ទើបពឹងឈ្មោះ [redacted] រ៉ាឌី, ឈ្មោះ [redacted] សាវណា និងឈ្មោះ [redacted] បញ្ញា ឲ្យខ្ចីជំនួស ដោយមានខ្ចី គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វានេន ១២.០០០ (មួយម៉ឺនពីរពាន់) ដុល្លារ និងខ្ចី ធនាគារ អេស៊ីដា ចំនួន ៣៥.០០០ (បីម៉ឺនប្រាំពាន់) ដុល្លារ ដាក់ឈ្មោះ [redacted] សាវណា និងខ្ចីគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ ចំនួន ១.២០០ (មួយពាន់ពីររយ) ដុល្លារ ដាក់ឈ្មោះ [redacted] បញ្ញា។ ឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ស្រីប៉ិច បានខ្ចីលុយធនាគារ ដោយយកប្លង់ដីខ្លួនដាក់ធានា ខ្ចីលុយធនាគារ អេស៊ីលីដា ចំនួន មួយម៉ឺនប្រាំពីរពាន់ដុល្លារ និងយក



Scanned with CamScanner

ប្លង់ដីសៀមរាប ខ្ចីលុយធនាគារ អេស៊ីលីដា ដាក់ឈ្មោះ [redacted] សំណាង និងឈ្មោះ [redacted] ស្រីប៉ិច ចំនួន បីម៉ឺនដុល្លារ ដែរ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] សំណាង បានធ្វើសេចក្តីថ្លែងការណ៍ថា សូមរក្សាចម្លើយរបស់កូនក្តីខ្លួន ដូចក្នុងកំណត់ហេតុត្រៀម ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៩ ដដែល គឺសុំលែងលះដដែល ទ្រព្យរួមមាន ដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាម ប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្ត សៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែង ទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្ត សៀមរាប គឺកូនក្តីខ្លួនយល់ព្រមលក់ ដើម្បីសងបំណុលធនាគារ ហើយលុយនៅសល់បែងចែងជា ពីរចំណែកស្មើគ្នា, កូនស្រីម្នាក់ឈ្មោះ [redacted] ដានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ យល់ព្រមប្រគល់ឲ្យឈ្មោះ [redacted] ស្រីប៉ិច ជាអ្នកមានសិទ្ធិអំណាចមេបា,ចំពោះបំណុលរួមកូនក្តីខ្លួន ទទួលស្គាល់តែបំណុលណាដែលមានឈ្មោះកូនក្តីខ្លួនប៉ុណ្ណោះ។ ចំពោះអាហារកាតព្វកិច្ចចិញ្ចឹម កូន គឺកូនក្តីខ្លួនបង់តាមលទ្ធភាពដដែល។

V.ចំណុចវិវាទៈ ទាក់ទងនឹងបំណុលរួមដែលត្រូវធ្វើការបែងចែក។

## សំអាងហេតុ

-តាមលទ្ធផលនៃការសាកសួរភាគី និងការពិនិត្យភស្តុតាងនានា នៅក្នុងនីតិវិធីទាញហេតុ ផលដោយផ្ទាល់មាត់ **ឃើញថា៖**

**១**-តាមពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែកក្កដា **ឆ្នាំ**២០១៨ របស់ឈ្មោះ [redacted] **សំណាង** និង បណ្តឹងតប ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា **៧៥** នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បី តុលាការយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន។

**២**-តាមសំបុត្រអាពាហ៍ពិពាហ៍ លេខ **១៥៨** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុ កូលដ្ឋាន សង្កាត់សំបួរ និងសំបុត្របញ្ជាក់កំណើត លេខ **២២៦** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់សំបួរ បញ្ជាក់បានថា ដើមចោទឈ្មោះ [redacted] សំណាង និងចុង ចម្លើយឈ្មោះ [redacted] ស្រីប៉ិច ពិតជាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមច្បាប់ និងជាឳពុក ម្តាយបង្កើតរបស់ឈ្មោះ [redacted] ដានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ ប្រាកដមែន គប្បី តុលាការលើកយកមកពិនិត្យ និងសម្រេចតាមការទាមទាររបស់ដើមចោទបាន។

**៣**-តាមសេចក្តីថ្លែងការណ៍របស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ បានបញ្ជាក់ថា ដើមចោទសុំលែងលះ ដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយ ខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី



Scanned with CamScanner

លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប គឺយល់ព្រមលក់ ដើម្បីសងបំណុលធនាគារ ហើយលុយនៅសល់បែងចែងជាពីរចំណែកស្មើគ្នា កូនស្រីម្នាក់ឈ្មោះ [redacted] ជានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ យល់ព្រមប្រគល់ឲ្យចុងចម្លើយ ជាអ្នកមានសិទ្ធិអំណាចមេបា ហើយអាហារកាតព្វកិច្ចចិញ្ចឹមកូនដើមចោទបង់តាមលទ្ធភាព ហើយចុងចម្លើយក៏បានយល់ព្រមលែងលះ ចំណែកទ្រព្យរួមមាន ដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប គឺយល់ព្រមលក់ ដើម្បីសងបំណុលធនាគារ ហើយលុយនៅសល់បែងចែងជាពីរចំណែកស្មើគ្នា ព្រមទទួលយកសិទ្ធិមានអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ជានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ និងយល់ព្រមឲ្យដើមចោទបង់អាហារកាតព្វកិច្ចចិញ្ចឹមកូន តាមលទ្ធភាព ដូច្នេះ ផ្អែកតាមបញ្ញត្តិមាត្រា **៩៧៩**, មាត្រា **១០៣៧** និងមាត្រា **១០៤០** នៃ**ក្រមរដ្ឋប្បវេណី** គប្បី តុលាការធ្វើការពិនិត្យ និងសម្រេចតាមការព្រមព្រៀង និងឆន្ទះរបស់គូភាគី។

**៤**-ចំពោះបំណុលដែលចុងចម្លើយបានបញ្ជាក់ថា ជាបំណុលរួម និងទាមទារឲ្យតុលាការ បែងចែងជាពីរចំណែកស្មើគ្នា ដូចក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ ឆ្លងតាមការពិនិត្យភស្តុតាង មានឯកសារ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ កាលវិភាគសងប្រាក់ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៦ និងកាលវិភាគសងប្រាក់ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ បញ្ជាក់ថា បំណុលដែលជាបំណុលរួមរវាងដើមចោទ និងចុងចម្លើយ មានបំណុលជំពាក់ធនាគារ អេស៊ីលីដា សរុប ចំនួន ៤៧.០០០ (បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក ចំណែកបំណុលផ្សេងទៀត គ្មានឯកសារបញ្ជាក់ថា ជាបំណុលរួមនោះទេ ដូច្នេះ ការទាមទាររបស់ចុងចម្លើយក្រៅពីនេះ គប្បី តុលាការច្រានចោល ព្រោះដើមចោទក៏បានបញ្ជាក់ដែរថា ដើមចោទទទួលស្គាល់ តែបំណុលណាដែលមានឈ្មោះខ្លួនប៉ុណ្ណោះ។

-ហេតុ**ដូច្នេះ យល់ឃើញថា** ដើមចោទ និងចុងចម្លើយពិតជាប្តីប្រពន្ធរស់នៅជាមួយគ្នាដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមច្បាប់ ដោយមានទ្រព្យសម្បត្តិរួម បំណុលរួម និងកូនស្រីម្នាក់ ដូចខាងលើ **ប្រាកដមែន** គប្បី តុលាការពិនិត្យ និងសម្រេចតាមពាក្យសុំដោយយោងលើឯកសារបញ្ជាក់ក្នុងសំណុំរឿង និងឆន្ទះព្រមព្រៀងរបស់គូភាគី។

**៥**-ប្រាក់ប្រដាប់ក្តី គប្បី តុលាការសម្រេចជាបន្ទុករបស់ភាគីដើមចោទ។



Scanned with CamScanner

## សម្រេចសេចក្ដីបញ្ចប់

**១**-ទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយឲ្យដើមចោទឈ្មោះ [redacted] សំណាង លែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីប៉ិច ចាប់ពីពេលសាលក្រមនេះចូលស្ថាពរ។

**២**-អោយចុងចម្លើយឈ្មោះ [redacted] ស្រីប៉ិច ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ១២០ (មួយរយម្ភៃ) ថ្ងៃ ស្របតាមមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

**៣**-ឲ្យចុងចម្លើយឈ្មោះ [redacted] ស្រីប៉ិច ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនស្រីឈ្មោះ [redacted] ដានី ភេទស្រី កើតនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ **តាមការព្រមព្រៀង**។

-ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងនឹងកូនបានគ្រប់ពេលវេលា ដើម្បីពិនិត្យមើលស្ថានភាពកូន ដោយភាគីដែលមានអំណាចមេបាមិនត្រូវរារាំងកូនមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយភាគីម្ខាងទៀត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត យោង តាមមាត្រា **១០៤០** និង មាត្រា **១០៤១** នៃក្រមរដ្ឋប្បវេណី។

**៤**-ទ្រព្យសម្បត្តិរួមមាន ដីមួយកន្លែងទំហំ ១៤ម៉ែត្រ គុណ ២០ម៉ែត្រ និងផ្ទះមួយខ្នង សង់នៅលើដីនោះ មានទំហំ ៦ម៉ែត្រ គុណ ១២ម៉ែត្រ ផ្ទះទាមប្រក់ស័ង្កសី មានក្បាលដី លេខ ៣៨៥ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានលេខ ៤៣០៣១០១ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ និងដីឡូត៍មួយកន្លែងទៀត មានទំហំ ១០ម៉ែត្រ គុណ ២៨ម៉ែត្រ ស្ថិតនៅ ភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប ខេត្តសៀមរាប ឲ្យភាគីដើមចោទ និងចុងចម្លើយលក់ ដើម្បីសងបំណុលរួមធនាគារ ហើយលុយដែលនៅសល់បែងចែកជាពីរចំណែកស្មើគ្នា **តាមការព្រមព្រៀង**។

**៥**-បំណុលរួមមាន បំណុលជំពាក់ធនាគារ អេស៊ីលីដា សរុប ចំនួន ៤៧.០០០ (បួនម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក បែងចែកជាពីរចំណែកស្មើគ្នា និងច្រានចោលបំណុលផ្សេងទៀត ក្នុងពាក្យបណ្ដឹងតប ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។

**៦**-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានឃើញ**

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅសៀមរាប,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៧កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅសៀមរាប,ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner